YUNNAN DAILY PRESS GROUP
No.178

# ប្រទេសចិន-ខេត្តយូនណាន

ទស្សនៈកម្ពុជា

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7903 ថ្ងៃសុក្រ ទី05 ខែមេសា ឆ្នាំ2019

## លោក យាន់ ឈឹងហ្វា អភិបាលខេត្តយូណាន:ជំរុញឱ្យវិស័យទេសចរណ៍ខេត្តយូណានជាប់លំដាប់លេខ១លើពិភពលោក

*អ្នកសារព័ត៌មាន បរទេសកំពុងសាកល្បងប្រើប្រាស់ កម្មវិធីAPP "ដើរលេងខេត្តយូនណាន" នៅវមណីយដ្ឋានព្រៃថ្ម*

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៩ កិច្ចប្រជុំស្តីពីការជំរុញការធ្វើបដិវត្តន៍ទេសចរណ៍ខេត្តយូណាន និងកិច្ចប្រជុំលើកទី១៥នៃក្រុមដឹកនាំការងារកម្មវិធី "ដើរលេងខេត្តយូណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" របស់ខេត្តយូនណាន បានបើកសម័យប្រជុំនៅក្រុងលីជាំង នៃខេត្តយូណានៗលោក យាន់-ឈឹងហ្វា អនុលេខាបក្សនិងជាអភិបាលខេត្តយូនណាន បានសង្កត់ធ្ងន់ថា យើងត្រូវប្រយ័ត្នស្មារតីនិងផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងសណ្តាប់ធ្នាប់ ទីផ្សារទេសចរណ៍ជាប់រហូតធ្វើឱ្យកាន់តែស៊ីជម្រៅនូវបដិវត្តន៍ទេសចរណ៍ និងលើកកម្ពស់គុណភាពនៃធាតុផ្សំទាំង ៦ នៃវិស័យទេសចរណ៍ដើម្បីជំរុញឱ្យវិស័យទេសចរណ៍ខេត្តយូនណាន ជាប់លំដាប់លេខ១ លើពិភពលោក ។

លោកបានគូសបញ្ជាក់ថា ក្នុងរយៈពេល២ឆ្នាំកន្លងទៅនោះ រដ្ឋបាលខេត្តយូនណាន បានខិតខំគ្រប់គ្រងសណ្តាប់ធ្នាប់ទីផ្សារទេសចរណ៍តាមរយៈការហាមមិនឱ្យរៀបចំក្រុមទេសចរណ៍ដែលមានតម្លៃទាបពេកនិងគ្រប់គ្រងការបង្ខំឱ្យភ្ញៀវទេសចរទិញវត្ថុអនុស្សាវរីយ៍ ជំរុញការអភិវឌ្ឍន៍នៃកម្មវិធីAPP"ដើរលេងខេត្តយូនណាន" ដែលបានជំរុញឱ្យឧស្សាហកម្មទេសចរណ៍ខេត្តយូនណានឈានដល់កម្រិតថ្មីមួយទៀត ។ រដ្ឋបាលក្រុងលីជាំង បានធ្វើបដិវត្តន៍ព័ត៌មានវិទ្យាគ្រប់ជ្រុងជ្រោយលើវិស័យទេសចរណ៍តាមរយៈកម្មវិធី"ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" ហើយបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងសណ្តាប់ធ្នាប់ទីផ្សារទេសចរណ៍ និងការផ្លាស់ទម្រង់អភិវឌ្ឍន៍នៃវិស័យទេសចរណ៍ខេត្តយូនណាន ។

លោក បានមានប្រសាសន៍ថា យើងត្រូវខិតខំលើកកម្ពស់គុណភាពនៃធាតុផ្សំទាំង ៦ លើវិស័យទេសចរណ៍ដើម្បីជំរុញឱ្យវិស័យទេសចរណ៍ខេត្តយូនណានជាប់លំដាប់លេខ ១ លើពិភពលោក ។ យើងត្រូវអនុវត្តន៍គម្រោង"បង្ហាញជាសាធារណៈនូវផ្ទះបាយនិងចង្ក្រាន" នៅទីប្រជុំទេសចរណ៍ បំបិទទ្វារនៃភោជនីយដ្ឋានដែលមិនបានចុះបញ្ជីពាណិជ្ជកម្ម ផ្តោតសំខាន់ទៅលើការត្រួតពិនិត្យដើម្បីលើកកម្ពស់ គុណ-ភាពនៃម្ហូបដែលផ្តល់ជូនទេសចរៗយើងត្រូវពន្លឿនការសាងសង់ សណ្ឋាគារផ្កាយ៥ ជំរុញការកំណត់ ស្តង់ដារអំពីសណ្ឋាគារប្រណីត និងផ្ទះសំណាក់ គ្រប់គ្រងតម្លៃនៃសណ្ឋាគារ និងផ្ទះសំណាក់ឱ្យស្របតាមស្តង់ដារ បទដ្ឋានដើម្បីលើកកម្ពស់គុណភាពនៃការស្នាក់នៅរបស់ទេសចរៗយើងត្រូវខិតខំដោះស្រាយបញ្ហាពិបាកជួលឡានជួលឡានដោយតម្លៃខ្ពស់ និងសង់ឡានទៅទីក្រុងផ្សេងជាដើមព្រមទាំងជំរុញការកែលម្អបរិស្ថាននៃតំបន់សម្រាកតាមផ្លូវល្បឿនលឿនឱ្យស្របតាមស្តង់ដារ និងការសាងសង់ផ្លូវស្អាតក្នុងតំបន់ទេសចរណ៍ ហើយត្រូវបង្កើត "ប្រព័ន្ធវេទិកាសេវាកម្មចម្រុះដែលមានច្រកតែមួយ"ដើម្បីលើកកម្ពស់នូវគុណភាពនៃការធ្វើដំណើររបស់ទេសចរ ។ យើងត្រូវខិតខំលើកកម្ពស់គុណភាពនៃតំបន់ទេសចរណ៍បង្កើតតំបន់គំរូនៃវិស័យទេសចរណ៍ក្នុងខេត្តទាំងមូល ដើម្បីលើកកម្ពស់នូវគុណភាពនៃការធ្វើទេសចរណ៍នៅខេត្តយូណានៗ យើងត្រូវផ្តល់កិច្ចធានាឱ្យទេសចរទិញទំនិញហើយអាចប្តូរយកលុយវិញដោយគ្មានលក្ខខណ្ឌក្នុងរយៈពេល៣០ថ្ងៃ ធានាគុណភាពទំនិញនិងតម្លៃសមហេតុផលហើយត្រូវដាក់ស្លាកតម្លៃទំនិញឱ្យបានច្បាស់ដើម្បីលើកកម្ពស់គុណភាពនៃការទិញទំនិញរបស់ទេសចរ ។ យើងត្រូវខិតខំអភិវឌ្ឍន៍ផលិតផលទេសចរណ៍ដែលមានពាក់ព័ន្ធនឹងវិស័យសុខភាព វប្បធម៌ កីឡា និងទំនៀមទម្លាប់ប្រពៃណីដើម្បីលើកកម្ពស់នូវគុណភាពនៃការលេងកម្សាន្តរបស់ទេសចរ ។

លោកសង្កត់ធ្ងន់ថា យើងត្រូវមានស្មារតីប្រុងប្រយ័ត្នពន្លឿនការកែលម្អប្រព័ន្ធកម្មវិធី"ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"សិក្សាស្រាវជ្រាវឱ្យបានកាន់តែស៊ីជម្រៅ អំពី "បណ្តាញ៥G" "ប្រព័ន្ធ AI" និងខ្សែសង្វាក់ប្លុក(Blockchain)ជាដើម បង្កើតជាប្រព័ន្ធ"ឌីហ្សីតាល+សេវាកម្មពិសេស"ដើម្បីផ្តល់គម្រោងវៃឆ្លាតសម្រាប់ការផ្លាស់ទម្រង់អភិវឌ្ឍន៍ នៃវិស័យទេសចរណ៍ និងធ្វើ ឱ្យខេត្តយូនណានដើរតួនាទីឈានមុខក្នុងវិស័យទេសចរណ៍វៃឆ្លាត ។

**ដោយលី សាវម៉ែង**

## ខេត្តយូណានរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការចិន-កម្ពុជា



*កម្មវិធីសម្តែងសិល្ប: "ស្នាមញញឹមអង្គរ" ដែលផលិតដោយ ក្រុមហ៊ុនវិនិយោគឧស្សាហកម្មវប្បធម៌ខេត្តយូនណាន "ក្រុងបុរីអាណិកជនចិន" បានត្រូវសម្តែងជាង៤.០០០លើក នៅប្រទេសកម្ពុជា*

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៩កម្មវិធី"ឆ្នាំវប្បធម៌-ទេសចណ៍ ចិន-កម្ពុជា"ឆ្នាំ២០១៩ បានបើកសម្ពោធនៅរាជធានីភ្នំពេញនៃប្រទេសកម្ពុជា។ ខេត្តយូណានជាខេត្តមួយរបស់ប្រទេសចិនដែលស្ថិតនៅជិតនឹងប្រទេសកម្ពុជាជាងគេ ។ កិច្ចសហប្រតិបត្តិការទេស-ចរណ៍រវាងខេត្តយូនណាននិងប្រទេសកម្ពុជា មានខ្លឹមសារដ៏សម្បូរដែលជាផ្នែកសំខាន់មួយនៃកិច្ចសហប្រតិបត្តិ-ការទេសចរណ៍រវាងប្រទេសចិននិងកម្ពុជា ។ នៅឆ្នាំ ២០១៩ខេត្តយូណាននឹងខិតខំក្តាប់ឱ្យជាប់នូវកាលានុវត្តភាពថ្មីនៃ"ឆ្នាំវប្បធម៌-ទេសចណ៍ចិន-កម្ពុជា" ដើម្បីរួមចំណែកក្នុងការពង្រឹងកិច្ច-សហប្រតិបត្តិការចិន-កម្ពុជា ។

លោកស្រីលី ចាស្យេន ប្រធានការិយាល័យសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវ:ទេសចរណ៍ខេត្តយូណានបានបញ្ជាក់ថា នៅចុងឆ្នាំទៅវិទ្យាស្ថានយើងខ្ញុំបានបញ្ជូនគណ:ប្រតិភូទៅប្រទេសកម្ពុជាដើម្បីរៀបចំវគ្គបណ្តុះបណ្តាលឱ្យមន្ត្រីរាជការ៣០រូប ដែលមកពីក្រសួងទេសចរណ៍កម្ពុជា ។ វគ្គបណ្តុះបណ្តាលនេះបានរៀបចំក្រោមប្រធានបទ "សហគ្រាសចិនចូលរួមនិងគាំទ្រការអភិវឌ្ឍវិស័យទេសចរណ៍និងប្រមូលធនធានទេសចរណ៍កម្ពុជាក្រោមក្រប-ខ័ណ្ឌខ្សែក្រវាត់មួយនិងផ្លូវមួយ" ។ ឆ្នាំ ២០១៩ជាឆ្នាំវប្បធម៌-ទេសចរណ៍ ចិន-កម្ពុជា ។ យើងខ្ញុំនឹងក្តាប់ឱ្យជាប់នូវកាលានុវត្តភាពថ្មីដើម្បីបង្កើនកិច្ចសហ-ប្រតិបត្តិការជាមួយភាគីកម្ពុជា ជំរុញការអនុវត្តគម្រោងកសាងវិទ្យាស្ថានជាតិទេសចរណ៍កម្ពុជាបន្តបង្កើតស្ថានមិត្ត-ភាពសម្រាប់ជំរុញការផ្លាស់ប្តូររវាងខេត្តយូនណាននិងប្រទេសកម្ពុជា ។ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវ:ទេស-ចរណ៍ខេត្តយូណានជាមូលដ្ឋានបណ្តុះបណ្តាលធនធានមនុស្សទេសចរណ៍ចិន-អាស៊ានតែមួយគត់ដែលអាជ្ញាធរជាតិទេសចរណ៍ចិនបានបង្កើតនៅខេត្តយូនណាន ។ វិទ្យាស្ថាននេះបានរួមសហការគ្នាជាមួយស្ថាប័នទេសចរណ៍កម្ពុជាក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលនិងអប់រំវិស័យទេសចរណ៍គ្រប់ប្រភេទ ។

ក្រុមហ៊ុនសាងសង់និងវិនិយោគខេត្តយូនណានគ្រុប បានធ្វើអាជីវកម្មនៅប្រទេសកម្ពុជា១ពាន្ធាំហើយ ។ លោក យីជា លេខាបក្សនៃក្រុមហ៊ុនសាងសង់ និងវិនិយោគខេត្តយូនណានសាខាកម្ពុជា បានគូសបញ្ជាក់ថា ក្រោយពីធ្វើអាជីវកម្មនៅប្រទេសកម្ពុជា ក្រុមហ៊ុនបានចូលរួមការសាងសង់អគាររដ្ឋបាលរាជរដ្ឋ-ភិបាលកម្ពុជា វិទ្យាស្ថានទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ (ដំណាក់-កាលទី៥) អគារថ្មីនៃស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា អគារការិយាល័យនៃក្រុមហ៊ុនអាកាសចរណ៍ JC កម្ពុជា និងផ្លូវថ្នល់នៅព្រលានយន្តហោះអន្តរជាតិខេត្តស្យេមរាបថ្មីជាដើម ហើយបានទទួលនូវពានរង្វាន់ដ៏ច្រើន។ ក្រុមហ៊ុនបានជួលបុគ្គលិកខ្មែរច្រើនផ្សព្វផ្សាយពីទស្សនៈទំនើប និងបទពិសោធន៍របស់ប្រទេសចិនព្រមទាំងបានបង្កើនចំណូលរបស់ប្រជាជនខ្មែរ។

នៅខែមករា ឆ្នាំ២០១៩ លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍កម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថានៅឆ្នាំ២០១៧ និង២០១៨ ប្រទេសចិនជាប្រភពទេសចរធំជាងគេរបស់កម្ពុជា។ ទេសចរចិនបានចាយប្រាក់ច្រើននៅកម្ពុជា ដែលបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចផ្តល់ការងារធ្វើ និងបង្កើតចំណូលលើវិស័យពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។ ឯកឧត្តមសង្ឃឹមថា កម្មវិធី "ឆ្នាំវប្បធម៌-ទេស-ចរណ៍" នេះនឹងអាចទាក់ទាញទេសចរដែលមកពីខេត្តយូនណាន និងខេត្តក្រុងផ្សេងៗទៀតនៃប្រទេសចិនឱ្យបានកាន់តែច្រើនមកដើរលេង និងធ្វើវិនិយោគនៅប្រទេសកម្ពុជា។

**ដោយលី ហ៊ីងឈាង**

## បរិមាណផ្កាស្រស់ខេត្តយូនណានជាប់លំដាប់លេខ១នៅប្រទេសចិនក្នុងរយៈពេល២៥ឆ្នាំជាប់គ្នា

តាមទិន្នន័យដែលប្រកាសដោយមន្ទីរកសិកម្ម និងជនបទខេត្តយូនណាននៅពេលចុងក្រោយបានឱ្យដឹងថា គិតមកដល់ឆ្នាំ២០១៨ បរិមាណផ្កាស្រស់ខេត្តយូនណានបានជាប់លំដាប់លេខ១ នៅប្រទេសចិនក្នុងរយៈពេល ២៥ឆ្នាំជាប់គ្នា ។ វិស័យផ្កាស្រស់របស់ខេត្តយូនណានកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស និងប្រកបដោយភាពពិពិធកម្ម រួមមានផ្កាស្រស់សម្រាប់ហូប ផ្កាសម្រាប់គយគន់ និងផ្កាជាវត្ថុធាតុដើមសម្រាប់កែច្នៃជាដើម។

*អ្នកពិនិត្យគុណភាព កំពុងជ្រើសផ្កាកុលាបដោយចៃដន្យ ដើម្បីធ្វើការ ពិនិត្យគុណភាពនៅមជ្ឈមណ្ឌលពាណិជ្ជកម្មអេឡិចត្រូនិកផ្កាទូវណានក្រុងគុនមីង (ដោយយ៉ាង ដឹង)*

## ខេត្តយូនណានរៀបចំកម្មវិធី "សប្តាហ៍ទន្លេឡានឆាង-មេគង្គ" ឆ្នាំ ២០១៩

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ សកម្មភាពអំពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គឆ្នាំ២០១៩ និងកម្មវិធី "សប្តាហ៍ទន្លេឡានឆាង-មេគង្គ" ឆ្នាំ ២០១៩ ដែលរៀបចំដោយសាលារដ្ឋបាលខេត្តយូនណាន បានប្រារព្ធនៅសាកលវិទ្យាល័យខេត្តយូនណាន។

នៅថ្ងៃទី១០ខែមករា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំនៃប្រទេសទាំង ៦ បានឯកភាពគ្នាលើការកំណត់យកសប្តាហ៍នៃការរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលលើកទី១ គឺសប្តាហ៍នៃថ្ងៃទី២៣ ខែមីនា ជារៀងរាល់ឆ្នាំជា "សប្តាហ៍ទន្លេឡានឆាង-មេគង្គ" ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គលើកទី២ ដែលរៀបចំនៅរាជធានីភ្នំពេញនៃព្រះរាជ-ណាចក្រកម្ពុជានាថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៨ ។ អំឡុងពេលពីថ្ងៃទី១៨ ដល់ទី២៤ ខែមីនា ឆ្នាំ២០១៩នេះ ជា "សប្តាហ៍ទន្លេឡានឆាង-មេគង្គ" ទី២ ។ ក្នុងឱកាសនេះ ប្រទេសទន្លេឡានឆាង-មេគង្គទាំង៦ នឹងរៀបចំសកម្មភាពមួយចំនួនធំ ដូចជា កិច្ចប្រជុំផ្លាស់ប្តូររវាងយុវជន ពិព័រណ៍សមិទ្ធផលសហប្រតិ-បត្តិការកម្មវិធីសម្តែងសិល្ប: និងវេទិកាឃ្លាំងគំនិត។ល។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ក្រោយពីបើកសម្ពោធនូវកម្មវិធី "សប្តាហ៍ទន្លេឡានឆាង-មេគង្គ" នេះ សកម្មភាពចំនួនជាង៣០ នឹងត្រូវរៀបចំជាបន្តបន្ទាប់រួមមាន សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ វេទិកាឃ្លាំងគំនិត អំពីការកសាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ និងកិច្ចប្រជុំតុមូលស្តីពីកិច្ចសហ-ប្រតិបត្តិការបរិស្ថានឡានឆាង-មេគង្គជាដើម។

**ដោយអ៊ូ ភីងហាន ឈឹងឃាន់ និងលី ចា**